រាជបណ្ឌិត្យសភាកម្ពុជា

# ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក
# (១៩៧៩-២០០៣)
# Cambodia-United States Relations 1979-2003

ទឹក មេច

និក្ខេបបទបណ្ឌិត

ឯកទេសៈ ប្រវត្តិវិទ្យា

២០១១

Scanned by CamScanner

រាជបណ្ឌិត្យសភាកម្ពុជា

# ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក
# (១៩៧៩-២០០៣)

## Cambodia-United States Relations 1979-2003

តីក មេង

និក្ខេបបទបណ្ឌិត

សាស្ត្រាចារ្យណែនាំ: បណ្ឌិតសភាចារ្យ ស៊ីន សំណាង

២០១១

Scanned by CamScanner

# មាតិកា


**ឧទ្ទិសស្នាដៃ** ........................................ vi
**សេចក្តីថ្លែងអំណរគុណ** ........................................ vii
**អំណះអំណាង** ........................................ viii
**មូលន័យសង្ខេប** ........................................ ix
**សង្ខេបនិក្ខេបបទ** ........................................ xv
**អារម្ភកថា** ........................................ xxv
**សេចក្តីផ្តើម** ........................................ ១
ក-លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១
ខ-ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ២
គ-គោលបំណងនៃការស្រាវជ្រាវ ........................................ ៣
ឃ-វិធនកំណត់នៃការស្រាវជ្រាវ ........................................ ៤
ង-វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៤
១-ការប្រមូលទិន្នន័យ ........................................ ៥
២-ការវាយតម្លៃទិន្នន័យ ........................................ ៥
៣-ការវិភាគទិន្នន័យ ........................................ ៥
ច-សារប្រយោជន៍នៃការស្រាវជ្រាវ ........................................ ៥
ឆ-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៦


## ជំពូកផ្តើម
## សហរដ្ឋអាមេរិក និងទំនាក់ទំនងអន្តរជាតិមុន និងក្រោយសង្គ្រាមលោកលើកទី២


១-ទ្រឹស្តីនៃទំនាក់ទំនងអន្តរជាតិ ........................................ ៩
២-ស្ថានភាពទូទៅនៃទំនាក់ទំនងអន្តរជាតិមុន និងក្រោយសង្គ្រាមលោកលើកទី២ .. ៩
២.១-ទំនាក់ទំនងអន្តរជាតិមុនសង្គ្រាមលោកលើកទី២ ........................................ ៩
២.១.១-ពិភពលោក និងទំនាក់ទំនងអន្តរជាតិពីឆ្នាំ១៩១៤-១៩១៨ ........................................ ៩
២.១.២-ទំនាក់ទំនងអន្តរជាតិក្រោយសង្គ្រាមលោកលើកទី១ ........................................ ៩
២.១.៣-ទំនាក់ទំនងអន្តរជាតិក្នុងសង្គ្រាមលោកលើកទី២ ........................................ ១១
៣-ទំនាក់ទំនងអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២ ........................................ ១២
៤-នយោបាយរបស់សហរដ្ឋអាមេរិក ចំពោះអាស៊ី ........................................ ១៥
៤.១-នយោបាយសហរដ្ឋអាមេរិក ចំពោះរុស្ស៊ី ........................................ ១៥
៤.២-នយោបាយរបស់សហរដ្ឋអាមេរិក ចំពោះអាស៊ីបូព៌ា ........................................ ១៦
៤.២.១-នយោបាយសហរដ្ឋអាមេរិក ចំពោះជប៉ុន ........................................ ១៧




Scanned by CamScanner

៤.២.២-នយោបាយសហរដ្ឋអាមេរិក ចំពោះចិន ........ ១៧
៤.២.៣-នយោបាយសហរដ្ឋអាមេរិក ចំពោះកូរ៉េ ........ ១៩
៥-នយោបាយរបស់សហរដ្ឋអាមេរិក ចំពោះឥណ្ឌូចិន ........ ១៩
៦-ការបង្កើតអង្គការសេអាតូ ........ ២២


## ជំពូកទី១
## ទំនាក់ទំនងកម្ពុជា-អាមេរិកមុនឆ្នាំ១៩៧៩


១-ទំនាក់ទំនងកម្ពុជា-អាមេរិក ពីចុងសតវត្សរ៍ទី១៩ដល់ឆ្នាំ១៩៥៤ ........ ២៤
២-ទំនាក់ទំនងកម្ពុជា-អាមេរិកពីឆ្នាំ១៩៥៤-១៩៧០ ........ ២៧
២.១-ទំនាក់ទំនងការទូត និងនយោបាយ ........ ២៧
២.១.១-ឯករាជ្យនៃប្រទេសកម្ពុជា និងនយោបាយពួកមហាអំណាច ........ ២៧
២.១.២-ការកសាងសេដ្ឋកិច្ច និងបញ្ហាទំនាក់ទំនងអន្តរជាតិ ........ ៣០
២.១.៣-ភាពមិនច្បាស់លាស់នៃនយោបាយការបរទេសកម្ពុជា ........ ៣២
៣-ជំនួយសហរដ្ឋអាមេរិកក្នុងសម័យសង្គមរាស្ត្រនិយម ........ ៤៤
៣.១-ជំនួយសេដ្ឋកិច្ច និងសង្គម ........ ៤៤
ក-សាធារណការ ........ ៤៤
ខ-ជំនួយផ្នែកសិក្សាធិការ ........ ៤៦
គ-ជំនួយផ្នែកសុខាភិបាល ........ ៤៨
ឃ-ជំនួយផ្នែករដ្ឋបាលសាធារណៈ ........ ៤៨
ង-ជំនួយផ្នែកមធ្យោបាយឃោសនា ........ ៤៩
៣.២-ជំនួយផ្នែកយោធា និងមហាផ្ទៃ ........ ៥០
ក-ជំនួយយោធា ........ ៥០
ខ-ជំនួយមហាផ្ទៃ ........ ៥០
៤-ទំនាក់ទំនងកម្ពុជា-អាមេរិក ១៩៧០-១៩៧៥ ........ ៥១
៤.១-ការទម្លាក់សម្ដេច នរោត្តម សីហនុ ........ ៥១
៤.២-ប្រតិកម្មរបស់ប្រជាពលរដ្ឋចំពោះរដ្ឋប្រហារ ........ ៦២
៤.៣-អំពើហិង្សាក្រោយព្រឹត្តិការណ៍រដ្ឋប្រហារ ........ ៦៣
៤.៤-ព្រឹត្តិការណ៍នយោបាយការទូត ........ ៦៤
៤.៥-នយោបាយការទូតនៅអង្គការសហប្រជាជាតិ ........ ៦៨
៤.៦-ការកាន់កាប់អំណាចរបស់លោក លន់ នល់ ........ ៧០
៤.៧-ចលនាតស៊ូរបស់សម្ដេច នរោត្តម សីហនុ ........ ៧១
៤.៧.១-ការរីកធំធាត់របស់ចលនាតស៊ូ ........ ៧១
៤.៧.២-ឥទ្ធិពលសម្ដេច នរោត្តម សីហនុ ........ ៧២




Scanned by CamScanner

៤.៧.៣-ឥទ្ធិពលនៃការទម្លាក់គ្រាប់បែក ........ ៧៣
៤.៧.៤-ទំនាក់ទំនងរវាងខ្មែរកុម្មុយនីស្ត និង វៀតណាមកុម្មុយនីស្ត ........ ៧៥
៤.៨-ភាពទន់ខ្សោយនៃការដឹកនាំរបស់ លន់ នល់ ........ ៧៧
៤.៩-សមរភូមិចុងក្រោយរវាងកងទ័ពលន់ នល់ និងកងទ័ពខ្មែរក្រហម ........ ៨៣
៤.១០-ជំនួយសហរដ្ឋអាមេរិក ........ ៨៥
៥-ការផ្តាច់ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក ឆ្នាំ១៩៧៥-១៩៧៩ ........ ៩០
៥.១-សោកនាដកម្មនៃសង្គ្រាម ........ ៩១
៥.២-សោកនាដកម្មក្នុងរបបខ្មែរក្រហម ........ ៩២


## ជំពូកទី២
## ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកឆ្នាំ១៩៧៩-១៩៩៣


១-ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ ៩៤
១.១-សភាពទ្រុឌទ្រោមរបស់ប្រជាជន ........ ៩៤
១.២-កាធ្វើវិសុទ្ធកម្ម ........ ៩៤
១.៣-ការប៉ះទង្គិចជាមួយវៀតណាម ........ ៩៥
២-នយោបាយការបទេសរបស់ប្រទេសកម្ពុជា ឆ្នាំ១៩៧៩-១៩៨៩ ........ ៩៦
២.១-តួនាទីរបស់រដ្ឋកម្ពុជា ........ ៩៧
២.២-តួនទីរបស់ភាគីខ្មែរតស៊ូ និងសម្ព័ន្ធមិត្ត ........ ៩៨
៣-ទំនាក់ទំនងសហរដ្ឋអាមេរិក និងចលនាចម្រុះត្រីភាគី ........ ១០៤
៣.១-តួនាទីសហរដ្ឋអាមេរិក ចំពោះចលនាចម្រុះត្រីភាគី ........ ១០៤
៣.២-ការផ្តល់ជំនួយរបស់សហរដ្ឋអាមេរិក ដល់ចលនាតស៊ូត្រីភាគី ........ ១០៥
៤-ដំណើរឆ្ពោះទៅរកសន្តិភាពនៅប្រទេសកម្ពុជា ឆ្នាំ១៩៨៧-១៩៩១ ........ ១១៣
៤.១-ស្ថានភាពជម្លោះនៅកម្ពុជា ........ ១១៣
៤.១.១-ការប្រែប្រួលនៃសកលលោក ........ ១១៥
៤.១.២-ការប្រែប្រួលនៃតំបន់ ........ ១១៦
៤.១.៣-ការប្រែប្រួលនៃជម្លោះរវាងខ្មែរ និងខ្មែរ ........ ១១៧
៤.២-ដំណើរការចរចាសន្តិភាពនៅកម្ពុជា ........ ១១៧
៤.២.១-ឥរិយាបទរបស់សហរដ្ឋអាមេរិក្នុងការចរចាជម្លោះកម្ពុជា ........ ១២២
៤.២.២-ការចរចាដោយមានការចូលរួមពីបណ្តាប្រទេសពាក់ព័ន្ធ ........ ១៣៩
៤.២.៣-ការចូលរួមពីសមាជិកអចិន្ត្រៃយ៍ទាំង៥ លើផែនការសន្តិភាពសម្រាប់កម្ពុជា ........ ១៤០
៤.២.៤-កិច្ចប្រជុំក្រៅផ្លូវការនៅហ្សាការតាលើកទី១ (JIM-I) ........ ១៤២
៤.២.៥-កិច្ចប្រជុំក្រៅផ្លូវការនៅហ្សាការតាលើកទី២ (JIM-II) ........ ១៤៣
៥-កិច្ចព្រមព្រៀងសន្តិភាពស្តីពីកម្ពុជានៅទីក្រុងប៉ារីស ........ ១៤៤




Scanned by CamScanner

៥.១-សន្និសីទអន្តរជាតិស្តីពីបញ្ហាកម្ពុជា នៅទីក្រុងប៉ារីស ............ ១៤៤
៥.២-កិច្ចប្រជុំក្រៅផ្លូវការនៅហ្សាការតាលើកទី១ ស្តីពីកម្ពុជា(IMCI)របស់(JIM-III)............ ១៤៦
៥.៣-កិច្ចប្រជុំរបស់ភាគីកម្ពុជា នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ............ ១៤៧
៥.៤-កិច្ចប្រជុំក្រៅផ្លូវការស្តីពីបញ្ហាកម្ពុជាលើកទី២ នៅហ្ស៊ីមគ ............ ១៤៩
៦-ការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ ............ ១៥៣
៦.១-សេចក្តីថ្លែងការណ៍ស្តីពីការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ............ ១៥៤
៦.២-តួនាទីអន្តរជាតិ និងនយោបាយសហរដ្ឋអាមេរិក ឆ្នាំ១៩៩១-១៩៩៣............ ១៥៦
៦.២.១-តួនាទីអន្តរជាតិ............ ១៥៦
៦.២.២-តួនាទីសហរដ្ឋអាមេរិក............ ១៥៧

## ជំពូកទី៣
## គោលនយោបាយអាមេរិក និងកម្ពុជាក្រោយសង្គ្រាមត្រជាក់

១-ភាពប្រសើរឡើងនៃនយោបាយការទូត ............ ១៦៣
២-នយោបាយការទូតក្រោយ ឆ្នាំ១៩៩៣............ ១៦៧
២.១-សន្តិភាព និងបញ្ហាខ្មែរក្រហមក្រោយការបោះឆ្នោត ឆ្នាំ១៩៩៣ ............ ១៦៨
២.១.១-សហរដ្ឋអាមេរិក និងបញ្ហាឧទ្ទាមខ្មែរក្រហម............ ១៦៨
២.១.២-សហរដ្ឋអាមេរិក និងការកាត់ទោសខ្មែរក្រហម............ ១៧៤
៣-ការជំរុញលទ្ធិប្រជាធិបតេយ្យ និងសិទ្ធមនុស្ស ............ ១៧៦
៣.១-សហរដ្ឋអាមេរិក និងស្ថានភាពប្រជាធិបតេយ្យ និងសិទ្ធមនុស្សនៅកម្ពុជា............ ១៧៦
៣.២-ជំនួយសហរដ្ឋអាមេរិកដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ............ ១៨៨
៣.២.១-ជំនួយថវិកាសម្រាប់ការបោះឆ្នោត ............ ១៨៨
៣.២.២-ជំនួយថវិកាសម្រាប់សិទ្ធមនុស្ស ............ ១៨៩
៤-ជំនួយសហរដ្ឋអាមេរិកសម្រាប់សន្តិសុខ និងសុវត្ថិភាព............ ១៩០
៤.១-ការជួញដូរគ្រឿងញៀន ............ ១៩០
៤.២-ការជួញដូរមនុស្ស............ ១៩២
៤.៣-ទំនាក់ទំនងយោធា និងការប្រឆាំងភេរវកម្ម............ ១៩៣
៤.៣.១-កិច្ចសហប្រតិបត្តិការសម្រាប់ការប្រឆាំងភេរវកម្ម............ ១៩៣
៤.៣.២-ការជួញដូរអាវុធ............ ១៩៥
៤.៣.៣-កិច្ចសហប្រតិបត្តិការផ្នែកយោធា............ ១៩៦
៥-ជំនួយសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍ ............ ១៩៧
៥.១-ជំនួយផ្នែកសុខាភិបាល............ ១៩៩
៥.២-ជំនួយផ្នែកអប់រំការអប់រំ និងវប្បធម៌ ............ ២០១
៥.២.១-ការអប់រំថ្នាក់មូលដ្ឋាន ............ ២០១
៥.២.២-ការអប់រំសម្រាប់និស្សិតថ្នាក់ឧត្តមសិក្សា ............ ២០២



Scanned by CamScanner

៥.២.៣-ជំនួយសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ..... ២០៣
៥.២.៤-ការអភិរក្សវប្បធម៌បុរាណ ..... ២០៤
៥.៣-ជំនួយសហរដ្ឋអាមេរិកសម្រាប់កិច្ចការប្រឆាំងបញ្ហាអំពើពុករលួយនៅកម្ពុជា ..... ២០៥
៥.៤-កម្មវិធីមនុស្សធម៌ គោលដៅទៅលើប្រជាពលរដ្ឋពិការកម្ពុជា ..... ២០៥
៥.៥-កម្មវិធីមនុស្សធម៌ ផ្តោតទៅលើគ្រោះធម្មជាតិ ..... ២០៦
៦-ជំនួយ និងទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ..... ២០៧
៦.១-ទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ..... ២០៧
៦.២-ជំនួយសម្រាប់កំណើនសេដ្ឋកិច្ច ..... ២០៩
សេចក្តីសន្និដ្ឋាន ..... ២១២
គន្ថនិទ្ទេស ..... ២១៥



Scanned by CamScanner

# មូលន័យសង្ខេប

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ សហរដ្ឋអាមេរិកបានដាក់ស្ថានឯកអគ្គរដ្ឋទូតនៅកម្ពុជា ហើយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៥៣ ដំណើរទស្សនកិច្ចរបស់អនុប្រធានាធិបតីសហរដ្ឋអាមេរិកបានមកដល់ប្រទេសកម្ពុជា។ ដូច្នេះយើងឃើញថា ចាប់តាំងពីពេលនោះមកចំណងទាក់ទងរវាងប្រទេសកម្ពុជា និង សហរដ្ឋអាមេរិកត្រូវបានពង្រឹង និងពង្រីកជាលំដាប់។ ប៉ុន្តែទំនាក់ទំនងនេះត្រូវបានកាត់ផ្តាច់ទៅវិញ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៦៥ និងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ម្តងទៀត ដោយសាររបបកម្ពុជាប្រជាធិតេយ្យប្រកាន់យកនយោបាយបិទទ្វារជាមួយនឹងបណ្តាពិភពលោកសេរី។ ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកមានភាពល្អកល្អើននឹងគ្នាឡើងវិញបន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋ នៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ដោយលោក លន់ នល់ និងទ្រង់ ស៊ីសុវត្ថិ សិរីមតៈ។ ក្រោយរដ្ឋប្រហារយើងសង្កេតឃើញថា សហរដ្ឋអាមេរិក បានប្រកាសគាំទ្រដល់របបលន់ នល់ និងទ្រង់ ស៊ីសុវត្ថិ សិរីមតៈ ហើយសហរដ្ឋអាមេរិកបានផ្តល់ជំនួយយោធា និងសេដ្ឋកិច្ចជាបន្ទាន់ដល់របបសាធារណរដ្ឋខ្មែរ ដើម្បីឱ្យពួកគេមានលទ្ធភាពស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ។ ម៉្យាងទៀតដើម្បីទប់ទល់នឹងចលនាកុម្មុយនីស្ត ដែលកំពង់រីកសាយនៅក្នុងប្រទេសកម្ពុជា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧០ លោកប្រធានាធិបតីសហរដ្ឋអាមេរិក និច សុន បានបញ្ជូនទាហានជំនាញអាមេរិក និងទាហានយួនខាងត្បូងចំនួន១៣០០០០នាក់ អមដោយរថក្រោះ កាំភ្លើងធំ យន្តហោះចម្បាំង និង គ្រឿងសព្វាវុធដ៏សម្បូរបែប ដើម្បីវាយកំទេចមូលដ្ឋានយួនកុម្មុយនីស្ត ដោយរារាំងមិនឱ្យទ័ពវៀតណាមកុម្មុយនីស្តរុលចូលជ្រៅមកក្នុងទឹកដីកម្ពុជា។

ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ យើងឃើញថា សហរដ្ឋអាមេរិកចាប់ផ្តើមមានទំនាក់ទំនងជាមួយរដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានសម្តេច នរោត្តម សីហនុ ជាប្រធាន។ ហើយចាប់ពីពេលនោះមកសហរដ្ឋអាមេរិក បានផ្តល់ជំនួយដល់រដ្ឋាភិបាលចម្រុះត្រីភាគីតាមរយៈប្រទេសចិន និងអាស៊ាន។ ហើយចាប់ពីឆ្នាំ១៩៨៧ មកស្ថានភាពនយោបាយនៅប្រទេសកម្ពុជាបានផ្លាស់ប្តូរ ហើយឈានទៅរកការចរចាដើម្បីបញ្ចប់ជម្លោះរវាងភាគីទាំងបួន។ ដំណើរការចរចានេះបានអូសបន្លាយពេលយ៉ាងយូរហូតដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទើបមានកិច្ចព្រមព្រៀងសន្តិភាពបញ្ចប់ជម្លោះ។

ទំនាក់ទំនងអន្តរជាតិក្នុងពេលនោះបង្ហាញពីការប្រឈមមុខដាក់គ្នារវាងប្លុកទាំងពីរ គឺប្លុកលោកសេរី(ដឹកនាំដោយសហរដ្ឋអាមេរិក)និងប្លុកកុម្មុយនីស្ត(ដឹកនាំដោយសហភាពសូវៀត)ដែលធ្វើឱ្យពិភពលោកជួបប្រទះនូវវិបត្តិជាច្រើន ដូចជា វិបត្តិសេដ្ឋកិច្ច នយោបាយ និងសង្គមជាដើម។ ម៉្យាងទៀតធ្វើឱ្យពិភពលោកទាំងមូលគ្មានស្ថេរភាព ហើយជាពិសេសគឺការរត់ប្រណាំងគ្នាផ្នែកសព្វាវុធ និងអាវុធ ប្រល័យលោក ដែលជាការគម្រាមកំហែងដាក់គ្នាលើសន្តិសុខពិភពលោកទាំងមូល។

ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក បានចាប់ផ្តើមឡើងវិញនៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពេលនោះសហរដ្ឋអាមេរិកបានផ្តើមធ្វើទំនាក់ទំនងឡើងវិញជាមួយនឹងចលនាតស៊ូត្រីភាគី ដែលគេចាត់ទុកថា ជាចលនាតស៊ូមិនមែនកុម្មុយនីស្ត។ តួនាទីរបស់សហរដ្ឋអាមេរិកនៅពេលនោះ គឺជួយដល់ចលនាតស៊ូត្រីភាគី ដើម្បីឱ្យពួកគេមានកម្លាំងយោធា



Scanned by CamScanner

និង សេដ្ឋកិច្ចគ្រប់គ្រាន់ក្នុងការតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានវៀតណាម ជាបង្អែកនៅពីក្រោយខ្នង។ ដោយឈរលើគោលការណ៍នេះហើយ ទើបសហរដ្ឋអាមេរិកចាប់ផ្តើមផ្តល់ជំនួយសង្គ្រោះ និងជំនួយយោធា ដល់ចលនាតស៊ូមិនមែនកុម្មុយនីស្តនៅឆ្នាំ១៩៨១ តែគេសង្កេតឃើញថា ជំនួយទាំងនោះក៏បានធ្លាក់ទៅដល់ដៃរបស់ក្រុមខ្មែរក្រហមផងដែរ ព្រោះនៅក្នុងចលនាតស៊ូត្រីភាគី គឺមានតែ កម្លាំងក្រុមខ្មែរក្រហមទេ ដែលមានកម្លាំងខ្លាំងជាងគេក្នុងការតស៊ូប្រឆាំងនឹងវត្តមានកងទ័ពវៀតណាម នៅកម្ពុជាបាន។ នៅឆ្នាំ១៩៨៥ សហរដ្ឋអាមេរិកបានផ្តល់ជំនួយចំនួន៥លានដុល្លារអាមេរិកដល់ចលនាតស៊ូត្រីភាគី ដើម្បីឱ្យពួកគេមានលទ្ធភាពតស៊ូប្រឆាំង នឹងវត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជា។ ក្រៅពីនោះសហរដ្ឋអាមេរិក ក៏ បានធ្វើការហ៊ុំព័ទ្ធសេដ្ឋកិច្ចមកលើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និង របបសាធារណរដ្ឋសង្គមនិយមវៀតណាមផងដែរ ដើម្បីឱ្យប្រទេសទាំងពីរនេះបន្ទន់ឥរិយាបថងាកមករកការចរចារដោយសន្តិវិធីវិញ។ នៅក្នុងដំណើរការចរចារនោះមានភាពស្មុគស្មាញ និង ការលំបាកជាច្រើន ពីព្រោះបញ្ហានេះ មានការទាក់ទងជាសំខាន់ ដល់ប្រទេសមហាអំណាចធំពីរ គឺសហភាពសូវៀត និង ប្រទេសចិន ដោយចិនមានគោលជំហរឹងមាំ ក្នុងការការពារដល់តួនាទីរបស់ខ្មែរក្រហមក្នុងការបែងចែកអំណាច។ ចំណែកឯសហភាពសូវៀត ក៏បានប្រកាន់នូវជំហរដ៏រឹងមាំផងដែរ ក្នុងការការពារដល់វៀតណាម និងរដ្ឋកម្ពុជានៅក្នុងឆាកអន្តរជាតិ។ ការមិនព្រមបន្ទន់ឥរិយាបថ នៃមហាអំណាចទាំងពីរនេះជាការលំបាកបំផុត ដែលធ្វើឱ្យជម្លោះរវាងភាគីទាំងបួននៅកម្ពុជាអូសបន្លាយរយៈយ៉ាងយូរ គឺចាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩១ ទើបមានកិច្ចព្រមព្រៀងសន្តិភាពបញ្ចប់ជម្លោះដ៏រាំរ៉ៃនេះ។ ក្រោយពីជំនួបរវាងលោក ប្រធានាធិបតី រេហ្គិន និង លោក ហ្គូបាឆូវ មក ធ្វើឱ្យសភាពការណ៍នៅកម្ពុជាមានការធូរស្រាលបន្តិច ហើយជាពិសេស យើងសង្កេតឃើញថាក្រោយពីការចុះខ្សោយនៃលិទ្ធិកុម្មុយនីស្តនៅឆ្នាំ១៩៨៩ ទើបការចរចារសន្តិភាពនៅកម្ពុជាមានភាពជាវិជ្ជមាន។ ទាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកមានភាពប្រសើរឡើងវិញ ក្រោយការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ ហើយនៅឆ្នាំ១៩៩៣ ជាលទ្ធផល យើងបានបង្កើតរាជរដ្ឋាភិបាលចម្រុះមួយ ដែលមានគណបក្សហ្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា ជាអ្នកដឹកនាំប្រទេស ក្នុងនោះសម្តេចក្រុមព្រះ នរោត្តម បុណ្ណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២។

នៅឆ្នាំ១៩៩៣ សហរដ្ឋអាមេរិកបានបើកស្ថានទូតជាផ្លូវការឡើងវិញនៅកម្ពុជា ហើយឯកអគ្គរដ្ឋទូតដំបូងរបស់សហរដ្ឋអាមេរិប្រចាំនៅកម្ពុជាគឺ លោក ឆាល ទ្វីនីង (Charles H Twining)។ សហរដ្ឋអាមេរិក បានចាប់ផ្តើមផ្តល់ជំនួយមនុស្សធម៌ និងជំនួយផ្នែកសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ ជាពិសេសជំនួយផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដូចជាការជួយកសាងឡើងវិញនូវផ្លូវជាតិលេខ៤ ពី ភ្នំពេញទៅកាន់កំពង់ផែក្រុងព្រះសីហនុ និងការកសាងផ្លូវមួយចំនួនទៀតទៅកាន់តំបន់ខ្មែរក្រហមរស់នៅ។ ការជួយផ្តល់អ្នកសង្កេតការណ៍អន្តរជាតិ (ជនជាតិអាមេរិក) មកជួយតាមដាន និងសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោតនៅទូទាំងប្រទេសកម្ពុជា នៅក្នុងពេលបោះឆ្នោតម្តងៗ បន្ទាប់ពីការបោះឆ្នោតជាសកលដែលរៀបចំដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣សហរដ្ឋអាមេរិកបានចូលរួមចំណែកក្នុងបង្កើតតុលាការអន្តរជាតិមួយ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម



Scanned by CamScanner

ហើយនៅទីបំផុត តុលាការនេះត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

សរុបមកទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក តាំងពីដើមរហូតមកដល់បច្ចុប្បន្ននេះ គេសង្កេតឃើញមានភាពល្អកល្អើនផង និងភាពល្អឹងជូរចត់ផងដែរ ព្រោះបណ្តាលមកពីនយោបាយការបរទេសនៃប្រទេសទាំងពីរ និងបណ្តាលមកពី ឥទ្ធិពលនៃសង្គ្រាមត្រជាក់ និងការជ្រៀតជ្រែកពីប្រទេសជិតខាងមកលើកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។



Scanned by CamScanner

## Abstract

On 25th June, 1952 America established the US embassy in Cambodia and on 30th October, 1953 vice president of America visited Cambodia. Since that time, the relationship between Cambodia and America had been strengthened and expanded gradually. But, this good relationship was cut off on 3rd May, 1965 and again on 17th April, 1975, because this was the regime of Democratic Kampuchea which Cambodia stopped communicating with liberal countries. Communication between Cambodia and America was being better after the coup d'état of the king Norodom Sihanouk from his chief of Cambodia by Mr Lon Nol and Sisovat Serei Matak on 18th March, 1970. After the coup d'état, America declared supporting to Mr Lon Nol and Sisovat Serei Matak, and America provided military aids and economic support to People's Republic of Kampuchea (PRK) regime for Cambodia restoration and development. Furthermore, this support was for resistance to communism which was wide spreading in Cambodia. On 30th April, 1970, president of America Mr Nixon provided skillful American soldiers and 130, 000 South Vietnamese soldiers in which included armored cars, artillery, battle planes, and other military equipments for destroying Vietnamese communist military base, and restricting Vietnamese communist invaded in Cambodia. This relationship was re-cut off when Khmer Rouge invaded in Phnom Penh on 17th April, 1975, and at that time People's Republic of Kampuchea (PRK) regime was ended.

Since Democratic Kampuchea had been collapsed on 7th January, 1979, government of America began communicating with the integration of government triangles which were King Norodom Sihanouk was a leader. Since that time, America had provided many supports to government triangles of Cambodia through China and Asian. Since 1987, Cambodia political situation had been changed and reached to negotiate for ending the conflict of four parties. The negotiation had spent for a long time, and until 23rd October, 1991, the conflict ending for peace agreement was created.

In 1993, Cambodia organized international election which was supported by the United Nations. As a result, Cambodia established an integrated government which was included FUNCINPEC party and Cambodian People Party (CPP) to lead the country, and in which Prince Norodom Ranarith was the first Prime Minister and Mr Hun Sen was the second Prime Minister.



Scanned by CamScanner

International relationship, at that time, showed about the confrontation of two bloc between liberal bloc, which was dominated by USA, and communist bloc, which was dominated by Soviet, and the world found many crises such as economic, politic, and social crises. In addition, the world was in instability, and the world competed in armaments and world destroying weapons which were threaten on global security.

Cambodia and America relationship was recreated when Democratic Kampuchea was collapsed on 7th January, 1979. At that time, America recreated friendship relationship with triangles struggle movement which was regarded as Non Communist Movement. The role of America at that time was supporting to that movement for ensuring that the movement had enough military and economic to against People's Republic of Kampuchea (PRK) which was supported by Vietnam. According to that principle, America provided rescue and military support to Non Communist Struggle Movement in 1981, but those supports were reached to Khmer Rouge group, because Khmer Rouge was the most powerful in triangles struggle movement to protest with Vietnamese soldiers in Cambodia. In 1985, America provided 5 million dollars to triangles struggle movement to increase the capacity of protesting with Vietnamese soldiers in Cambodia. Furthermore, America did restriction on the economy of People's Republic of Kampuchea (PRK) regime, and People's Republic of Vietnam in order to make these countries turned their mind to get non violence negotiation. The negotiation of these two countries was very complex and difficult because it related to two powerful countries those were Soviet and China. China had strong commitment on protecting of Khmer Rouge's role in dividing power. Soviet also had strong commitment in protecting Vietnam and Kampuchea State regime in international meeting. Unwillingness to stop their serious confrontation of the two powerful countries was the most difficult for ending conflict of four parties in Cambodia, and it had to spend long time from 1979 to 1991 to get peace agreement and ending that chronic conflict.

After the meeting between president Reagan and Gobacheiv, Cambodia situation was being better; especially, after decreasing of popular of communism in 1989, negotiation in Cambodia was being positive. Relationship between Cambodia and America was being better after free and justice election organized by the United Nations in 1993. In 1993, America re-established official embassy in Cambodia, and the first American ambassador in Cambodia was Mr Charles .H Twining. America provided humanitarian and economy supports for development in Cambodia;



Scanned by CamScanner

especially, the infrastructure development such as re-construction National Road number 5 from Phnom Penh to Sihanouk port, and the construction of other roads to Khmer Rouge living area. America provided international investigators (American) to monitor and investigate in election office in Cambodia while election time. After the election was organized by the United Nations in 1993, America contributed in establishing international court to sentence Khmer Rouge leaders, and this court was created on 6th June, 2003.

In short, relation between Cambodia and America since the past until now was good and bad, because of these two countries' foreign affairs political situation, and it was because of the Cold War and interference of neighbor countries in internal Cambodia politic.



Scanned by CamScanner

# សង្ខេបនិក្ខេបបទ

ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិកបានចាប់បដិសន្ធិឡើងដំបូងនៅចុងសតវត្សទី១៩ ហើយក្រោយមកលោក ឆាល ទ្រីឡែត (Charles Trewlett) ដែលជាពាណិជ្ជករ និងជាតំណាងឱ្យស្ថានកុងស៊ុលសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងព្រៃនគរ បានផ្តួចផ្តើមគំនិតស្ថាបនាទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិក។ ទំនាក់ទំនងដំបូងនេះមានរូបភាពជាផ្នែកពាណិជ្ជកម្មប៉ុណ្ណោះ ពីព្រោះ សហរដ្ឋអាមេរិកត្រូវការពង្រីក ពាណិជ្ជកម្ម ជាពិសេស គឺពាណិជ្ជកម្មប្រេងឥន្ធនៈកេរ៉ូសែន (US Kerosene) មកកាន់ប្រទេសទាំងឡាយ នៅឥណ្ឌូចិន។

មូលហេតុចម្បងនៃទំនាក់ទំនងនេះ គឺអាស្រ័យដោយសហរដ្ឋអាមេរិក មានគោលបំណងពង្រីកវិស័យពាណិជ្ជកម្មប្រេងឥន្ធនៈមកកាន់ប្រទេសនៅឥណ្ឌូចិន។ ហេតុដូច្នេះហើយ ទើបនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៨៨៩ រដ្ឋាភិបាលសហរដ្ឋអាមេរិក បានតែងតាំងលោក អេមី ហ្វ្រង់សាឡែស (Aimee Fonsales) ឱ្យធ្វើជាភ្នាក់ងារទទួលបន្ទុកផ្នែកពាណិជ្ជកម្ម ប្រចាំឥណ្ឌូចិន។ បន្ទាប់មកទៀត នៅខែមិថុនា ឆ្នាំ១៩០៦ សហរដ្ឋអាមេរិកបានបើកស្ថានកុងស៊ុលរបស់ខ្លួននៅទីក្រុងព្រៃនគរ ដោយបានតែងតាំង លោក ភើលី ស៊ីហ៊ីល (Perley C Heald) ជាប្រធាន។

នៅក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ (១៩០៤-១៩២៧) ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក បានធ្វើឡើងជាលក្ខណៈទំនាក់ទំនងផ្នែកការទូត ហើយចាប់ផ្តើមមានទស្សនកិច្ចមកកាន់ប្រទេសកម្ពុជានូវឥស្សរជនសំខាន់ៗនៃសហរដ្ឋអាមេរិក។ ជាក់ស្តែងនៅឆ្នាំ១៩០៨ លោក ខនណើ (Conner) និង សមាជិករបស់លោក បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា នេះគឺជាវត្តមានអ្នកការទូតសហរដ្ឋអាមេរិកនៅលើទឹកដីកម្ពុជា ជាលើកដំបូង។ ហើយក្រោយមកទៀត នៅឆ្នាំ១៩១៥ គេសង្កេតឃើញមានទស្សនកិច្ចរបស់មន្ត្រីសហរដ្ឋអាមេរិក មកកាន់ទីក្រុងភ្នំពេញ តាមមហាវិថីមួយដែលភ្ជាប់ពីទីក្រុងព្រៃនគរមកកាន់ទីក្រុងភ្នំពេញ។ ម៉្យាងទៀតនៅឆ្នាំ១៩២៥ លោក ហ៊ីតតុន ទ្រីតវេត (Heaton Treadway) ដែលជាសមាជិកសភាសហរដ្ឋអាមេរិកលើកដំបូង បានធ្វើដំណើរមកបំពេញទស្សនកិច្ចជាផ្លូវការនៅទីក្រុងភ្នំពេញ។ ហើយលោក ហ៊ីតតុន ទ្រីតវេត (Heaton Treadway) ក៏បានចូលគាល់ព្រះមហាក្សត្រប្រទេសកម្ពុជា ព្រមទាំងបានថ្វាយសារតាំងដល់ព្រះមហាក្សត្រទៀតផង។

នៅចុងសម័យកាលគ្រប់គ្រងរបស់អាណាព្យាបាលបារាំង យើងឃើញថា បើទោះបីជាប្រទេសក្នុងឥណ្ឌូចិន កំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសបារាំងក៏ដោយ ក៏សហរដ្ឋអាមេរិកនៅតែព្យាយាមធ្វើទំនាក់ទំនងការទូតជាមួយប្រទេសទាំងនោះដែរ។ ជាពិសេសនៅឆ្នាំ១៩៥០ សហរដ្ឋអាមេរិក បានធ្វើទំនាក់ទំនងការទូតដោយផ្ទាល់ជាមួយប្រទេសកម្ពុជា ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ ទំនាក់ទំនងនេះកាន់តែប្រសើរឡើង រហូតដល់មានបើកទីស្នាក់ការទូត និងមានមន្ត្រីទូតឈ្មោះ រ៉ូបែត ម៉ាកគ្លីនថក (Robert MaClintock) ជា ឯកអគ្គរដ្ឋទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ បើផ្អែកតាមទស្សនៈ របស់ លោក គ្រីតហ្គ័រី (Gregory Lawless) បានបង្ហាញថា "សហរដ្ឋអាមេរិកមានទំនាក់ទំនងការទូតផ្លូវការដំបូង ជាមួយប្រទេសកម្ពុជា នៅឆ្នាំ១៩៥៥ ហើយទំនាក់ទំនងនេះ ត្រូវប្រេះឆារទៅវិញពីឆ្នាំ១៩៦៥-១៩៦៩"។ បន្ទាប់ពីមានទំនាក់ទំនងការទូតនោះមក យើងសង្កេតឃើញថា ចាប់ពីឆ្នាំ១៩៥៥មក សហរដ្ឋអាមេរិក បានចាប់ផ្តើមផ្តល់កម្មវិធីជំនួយជាច្រើន ដល់ប្រទេសកម្ពុជា



Scanned by CamScanner

ដែលមានទឹកប្រាក់ប្រមាណជាង៥០ លានដុល្លារក្នុង១ឆ្នាំ។ ក្រោយពីបានភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការជាមួយប្រទេសកម្ពុជានៅឆ្នាំ១៩៥២មក សហរដ្ឋអាមេរិកបានផ្តល់ជំនួយដើម្បីស្តារ និងអភិវឌ្ឍន៍វិស័យអប់រំឱ្យមានការរីកចម្រើនឡើងវិញ ហើយជំនួយនេះត្រូវបានគេបែងចែកទៅតាមបណ្តាឆ្នាំនីមួយៗ ដោយគិតចាប់ពីឆ្នាំ ១៩៥៥ ដល់ ១៩៦២ ។ ជាក់ស្តែងរួមមាន ៖

ឆ្នាំ១៩៥៥ ៖ ៦០០.០០០ ដុល្លារ ឆ្នាំ១៩៥៦ ៖ ១.៥០០.០០០ ដុល្លារ ឆ្នាំ១៩៥៧ ៖ ២.៧០០.០០០ដុល្លារ ឆ្នាំ១៩៥៨ ៖ ១.៥០០.០០០ដុល្លារ ឆ្នាំ១៩៥៩ ៖ ២.៤០០.០០០ដុល្លារ ឆ្នាំ១៩៦០ ៖ ២.៦០០.០០០ ដុល្លារ ឆ្នាំ១៩៦១ ៖ ៥.៥០០.០០០ ដុល្លារ និងឆ្នាំ១៩៦២ ៖ ៦.៣០០.០០០ ដុល្លារ។

ចំពោះប្រាក់ជំនួយដែលគ្រោងទុកសម្រាប់ឆ្នាំ១៩៦១-១៩៦២ មិនទាន់បានចំណាយនៅឡើយ ក្នុងនោះមានទាំងប្រាក់សម្រាប់ចំណាយស្ថាបនាវិទ្យាស្ថានបច្ចេកទេស សំណង់ស្ថាបនាសាលាជាតិផ្នែកសិល្បៈ និងមុខរបរ សម្រាប់មជ្ឈមណ្ឌលថ្មីខាងគរុកោសល្យនៅខេត្តសៀមរាប និងសម្រាប់អនាគតវិទ្យាល័យមិត្តភាពខ្មែរ-អាមេរិកកាំង។ ដោយឡែកចំពោះប្រទេសចិនវិញបានជួយស្ថាបនាសាលាបឋមសិក្សាដែលមានទឹកប្រាក់ទាំងអស់ចំនួន ៤២លានរៀល។ ចំណែកសហភាពសូវៀតបានជួយស្ថាបនាវិទ្យាស្ថានបច្ចេកទេស ក្រុមមូលនិធិអាស៊ីបានជួយទិញសៀវភៅ សម្ភារៈសិក្សា និងបញ្ជូននិស្សិតទៅរៀនឯបរទេស សរុបទឹកប្រាក់ចំនួន ៦.៨១០. ០០០រៀល។ ក្រៅពីនេះនៅមានការឧបត្ថម្ភទៅលើការអប់រំសម្រាប់ជនបទ ដែលផ្សាភ្ជាប់ទៅនឹងកិច្ចអភិវឌ្ឍន៍ជនបទ។ មជ្ឈមណ្ឌលរបស់ជាតិមួយសម្រាប់ការអប់រំមូលដ្ឋាន ត្រូវបានបង្កើតឡើងនៅទន្លេបាទី ដោយកិច្ចសហប្រតិបត្តិការពីយូណេស្កូ (UNESCO) អង្គការសុខភាពពិភពលោក (O.M.S) អង្គការស្បៀងអាហារពិភពលោក (F.A.O) និងរាជរដ្ឋាភិបាលកម្ពុជា មជ្ឈមណ្ឌលនេះមានគោលដៅអប់រំទៅលើគោលការណ៍វិធីសាស្ត្រ និងបច្ចេកទេសសម្រាប់ការអភិវឌ្ឍភូមិ ដោយទទួលអប់រំបណ្តុះបណ្តាលគ្រូចំនួន ២៥០នាក់ មកពីខេត្តចំនួន ១៤ ដែលជាក្រុមគ្រូចល័ត ចុះអប់រំមនុស្សចាស់នៅតាមភូមិនានា តាមបែបផែនជាសាលាបង្ហាញគំរូជាក់ស្តែង។

ហើយក្រោយមកដោយសារសហរដ្ឋអាមេរិក បានឃុបឃិតជាមួយសម្ព័ន្ធមិត្តដូចជា វៀតណាមខាងត្បូង និង ប្រទេសថៃរៀបចំផែនការនៅក្នុងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញដើម្បីធ្វើការគៀបសង្កត់លើផ្នែកនយោបាយ និងសេដ្ឋកិច្ចមកលើរបបដឹកនាំរបស់ សម្តេច នរោត្តម សីហនុ តែត្រូវបរាជ័យទៅវិញ ដែលជាដើមចមជំរុញឱ្យស្ថានភាពទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ឈានទៅរកការផ្តាច់ទំនាក់ទំនងទូតទាំងស្រុង នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៦៥។ ហើយចាប់ពីដំណើរទស្សនកិច្ចពីថ្ងៃទី២ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ របស់លោកជំទាវ ចេកឃ្វៃលីន ខេនណឺឌី (Jacqueline Kennedy)មកទីក្រុងភ្នំពេញ ដែលមានការទទួលស្វាគមន៍ពីសម្តេច នរោត្តម សីហនុ ទំនាក់ទំនងនៃប្រទេសទាំងពីរផ្តើមមានចំណងល្អនឹងគ្នាឡើងវិញ រហូតដល់មានការបើកស្ថានទូតអាមេរិកឡើងវិញ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦៩។ បន្ទាប់ពីការធ្វើ រដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ដោយលោក លន់ នល់មក សហរដ្ឋអាមេរិកបន្តផ្តល់ជំនួយយ៉ាងច្រើនដល់រដ្ឋាភិបាល លន់ នល់ តាំងពីឆ្នាំ១៩៧០-១៩៧៥។ ចាប់ពីឆ្នាំ ១៩៧៥ មក ទំនាក់ទំនងការទូត



Scanned by CamScanner

រវាងប្រទេសទាំងពីរត្រូវផ្តាច់ទាំងស្រុង ដោយរបបកម្ពុជាប្រជាធិបតេយ្យ អនុវត្តន៍នយោបាយបិទទ្វារជាមួយពិភពលោកសេរី។

បេសកកម្មសហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញ បានចាប់ផ្តើមឡើងវិញនាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ យោងតាមស្មារតីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សហរដ្ឋអាមេរិកបានរក្សានូវ វត្តមានរូបវន្តរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ទំនាក់ទំនងការទូតពេញលេញមួយ បានបង្កើតឡើងបន្ទាន់ផងដែរ ក្រោយប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ហើយបានរៀបចំរាជរដ្ឋាភិបាលចម្រុះមួយនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៤ ឯកអគ្គរដ្ឋទូតដំបូងរបស់សហរដ្ឋអាមេរិក ក៏បានមកធ្វើការនៅប្រទេសកម្ពុជាផងដែរ គឺ លោកឆាល ទ្វីនីង (Charles H. Twining)។

ចាប់ពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន សហរដ្ឋអាមេរិកបានចាត់តាំងឯកអគ្គរដ្ឋទូតចំនួន០៦រូបមកបំពេញបេសកកម្មការទូតនៅប្រទេសកម្ពុជា ហើយបេសកកម្មការទូតទាំងនោះផ្តោត ជាពិសេសទៅលើគោលដៅ នៃគោលនយោបាយការបរទេសរបស់សរដ្ឋអាមេរិកដូចៗគ្នា ពោលគឺ ការពារទឹកដីសហរដ្ឋអាមេរិក និងពលរដ្ឋអាមេរិកនៅបរទេស។ សហរដ្ឋអាមេរិក ចង់បានទំនាក់ទំនងជាមួយកម្ពុជា ដោយសន្តិវិធី និងអភិវឌ្ឍន៍ ក្នុងបំណងសម្រេចឱ្យបាននូវសន្តិសុខក្នុងតំបន់ និងពិភពលោក។

គោលបំណងសំខាន់របស់សហរដ្ឋអាមេរិក នៅក្នុងប្រទេសកម្ពុជាមិនមានលក្ខណៈធំដុំទេ ប៉ុន្តែជាប្រទេសសំខាន់ផ្នែកយុទ្ធសាស្ត្រសម្រាប់សហរដ្ឋអាមេរិក ជាពិសេស ការជំរុញនីតិរដ្ឋ, ប្រជាធិបតេយ្យ, សិទ្ធិមនុស្ស, ទប់ស្កាត់អំពើភេរវកម្ម, ការសម្របសម្រួលពាណិជ្ជកម្ម និងការនាំយកអតីតមេដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោស។ គោលបំណងនេះ ក៏មិនខុសពីគោលបំណងរបស់សហរដ្ឋអាមេរិក ចំពោះតំបន់អាស៊ីទាំងមូលដែរ ពោលគឺ ទី១ សន្តិសុខ តាមរយៈការគោរពនីតិរដ្ឋ និងការប្រយុទ្ធប្រឆាំងការគម្រាមកំហែងអន្តរជាតិ ដូចជា ភេរវកម្ម គ្រឿងញៀន ជំងឺអេដស៍ និងជំងឺគ្រុនផ្តាសាយបក្សី ទី២ ភាពសម្បូរុងរឿងតាមរយៈសេរីភាពខាងការធ្វើពាណិជ្ជកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ទី៣ ការគាំទ្រលទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស។ ទាំងអស់នេះ ក៏បានឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍សហរដ្ឋអាមេរិក ចំពោះពិភពលោកទាំងមូលដែលរួមមាន ទី១- ការបង្កើនជំនួយផ្នែកហិរញ្ញវត្ថុ ដល់បណ្តាប្រទេសដែលក្រីក្រ ទី២-ផ្តល់នូវជំនួយបន្ថែមទៀត និងការកែទម្រង់នូវការផ្តល់ជំនួយ ទី៣- កំណត់នូវលទ្ធផល នៃកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយឱ្យបានយ៉ាងហ្មត់ចត់ និង ទី៤- កំណត់គោលដៅកិច្ចគាំទ្រដល់បណ្តាប្រទេសនានាដែលមានយុទ្ធសាស្ត្រ នៃការលូតលាស់ជាមុន។

ចំណែកឯគោលដៅ នៃគោលនយោបាយការបរទេសស្នូល របស់សហរដ្ឋអាមេរិក ចំពោះប្រទេស កម្ពុជា នាសហសម័យនេះមាន ៥ចំណុចសំខាន់ ៖

១- ការរក្សាឱ្យមានស្ថិរភាព និងសន្តិភាព ២- ការរក្សាសុវត្ថិភាព

៣- ការជំរុញឱ្យមានការរីកចម្រើន ៤- ផ្តោតលើការគម្រាមគំហែង ដូចជា អំពើភេរវកម្ម និង

៥- ជំរុញលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស

ដូច្នេះឃើញថា គោលនយោបាយទាំងនេះ កំពុងឆ្លើយតបនឹងបច្ចុប្បន្នភាពនៃកម្ពុជា ដែលរាជរដ្ឋាភិបាលកំពុងរៀបចំបទដ្ឋានគតិយុត្តិឱ្យប្រទេសនេះមាននីតិរដ្ឋ ក្នុងបំណងអភិវឌ្ឍន៍ប្រទេសឱ្យរីក



Scanned by CamScanner

ចម្រើនជឿនលឿន។

ម្យ៉ាងទៀត យើងសូមបង្ហាញនូវសកម្មភាព នៃគោលនយោបាយការបរទេសសហរដ្ឋអាមេរិក ចំពោះ ប្រទេសកម្ពុជា ដូចខាងក្រោម ៖

